រកត/០៣០៥/១៤៩

# ព្រះរាជក្រឹត្យ

## ស្តីពី

## ការកំណត់ប្រភេទសត្វ និង រុក្ខជាតិ សម្រាប់ជានិមិត្តរូប នៃព្រះរាជាណាចក្រកម្ពុជា

☆☆☆☆☆

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**

**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ ខេមរជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២ /នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី ២៤ ខែធ្នូ ឆ្នាំ ១៩៩៦ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និង ការគ្រប់គ្រងធនធានធម្មជាតិ
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី ៣១ ខែសីហា ឆ្នាំ ២០០២ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ដែលបានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០០៥

# ត្រាស់បង្គាប់

**មាត្រា ១.-**

ព្រះរាជក្រឹត្យនេះ មានគោលបំណងកំណត់ឈ្មោះសត្វ និង រុក្ខជាតិ ដែលមានអត្តិភាព និង សារប្រយោជន៍ពិសេស សម្រាប់ជានិមិត្តរូបនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីបង្ហាញនូវមរតកធម្មជាតិដ៏មានតម្លៃ និង លើកតម្កើងនូវមោទនភាពជាតិ ។

**មាត្រា ២.-**

សត្វ និង រុក្ខជាតិ សម្រាប់ជានិមិត្តរូបនៃព្រះរាជាណាចក្រកម្ពុជា មានឈ្មោះទៅតាមប្រភេទដូចខាងក្រោម :

| | | |
|---|---|---|
| ១- ប្រភេទសត្វចតុប្បាទ | : | សត្វគោព្រៃ |
| ២- ប្រភេទបក្សី | : | សត្វត្រយ៉ង |
| ៣- ប្រភេទឧរង្គសត្វ | : | អណ្តើកសរសៃ - អណ្តើកហ្លួង |
| ៤- ប្រភេទមច្ឆា | : | ត្រីគល់រាំង |
| ៥- ប្រភេទរុក្ខជាតិ | : | ដើមត្នោត |
| ៦- ប្រភេទផ្កា | : | ផ្ការំដួល |
| ៧- ប្រភេទផ្លែឈើ | : | ផ្លែចេកពងមាន់ |

រូបភាព និង លក្ខណៈវិនិច្ឆ័យនៃសត្វ និង រុក្ខជាតិនីមួយៗ ដូចចែងខាងលើ មានភ្ជាប់ក្នុងឧបសម្ព័ន្ធទី១ ទី២ ទី៣ ទី៤ ទី៥ និង ទី៦ នៃព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣.-**

សត្វ និង រុក្ខជាតិ ដូចមានចែងក្នុងមាត្រា២ ខាងលើ ត្រូវមានវិធានការថែរក្សាការពារ អភិរក្សឱ្យមាននិរន្តរភាព និង ត្រូវផ្សព្វផ្សាយឱ្យបានទូលំទូលាយ ។

**មាត្រា ៤.-**

សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៥.-**

ព្រះរាជក្រឹត្យនេះ មានអានុភាពអនុវត្ត ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ធ្វើនៅព្រះបរមរាជវាំង, រាជធានីភ្នំពេញ ថ្ងៃទី២១ ខែមីនា ឆ្នាំ២០០៥

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
ព្រះមហាក្សត្រ សូមឡាយព្រះហស្តលេខា
នាយករដ្ឋមន្ត្រី
ហត្ថលេខា
ហ៊ុន សែន

៣រល.០៥០៣

លេខ ១២៤.ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ ៣ ឆ្នាំ២០០៥
អគ្គលេខាធិការរាជរដ្ឋាភិបាល
[illegible] តាន់

# ឧបសម្ព័ន្ធទី៥

## នៃព្រះរាជក្រឹត្យលេខនស/រកត/០៣០៥/១៤៩ ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០០៥

## ស្តីពីការកំណត់ប្រភេទសត្វ និងរុក្ខជាតិសម្រាប់ជានិមិត្តរូបនៃព្រះរាជាណាចក្រកម្ពុជា

---

### ៥-ដើមត្នោត (Borassus flabellifer) ជារុក្ខជាតិនិមិត្តរូបនៃព្រះរាជាណាចក្រកម្ពុជា



ឈ្មោះ ជាភាសាជាតិ "**ត្នោត**" ។ វាមានឈ្មោះវិទ្យាសាស្ត្រ "**Borassus flabellifer**" និងជាភាសាអង់គ្លេស គឺ "**Sugar Palm**" ។ ត្នោតជាប្រភេទរុក្ខជាតិបិតក្នុងតាលព្រឹក្សខ្ពស់ មានដើមទោល គល់ធំដុះត្រង់ឡើងលើ កម្ពស់ពី១០-២០ម៉ែត្រ ឫសវាមានលក្ខណៈជាឫសរយោង និងគ្មានឫសកែវ ។ តួដើមត្នោតមានភាពគគ្រើម ពណ៌ក្រម៉ៅ អង្កត់ផ្ចិតពី២០-៦០សង្ទី ម៉ែត្រ ដោយប្រែប្រួលទៅតាមគុណភាពដី ។ កន្សោមស្លឹកមានរាងដូចផ្លិត ប្រមូលផ្តុំគ្នានៅផ្នែកចុងកំពូលនៃដើម ។ ធាងត្នោតរលោង ក្រាស់ មានពណ៌លឿង បៃតងពេលនៅខ្ចី និងលឿងត្នោតពេលមានអាយុចាស់ ព្រមទាំងមានបន្លានៅគែមទាំងសងខាងសណ្ឋានដូចជាធ្មេញរណារ ។ ត្នោតញី និងឈ្មោលមានលក្ខណៈខុសប្លែកគ្នាតាមការសម្គាល់លើផ្ការបស់វា ។ ផ្កាត្នោតឈ្មោលមានរាងមូលទ្រវែង ទំហំពី២-៤សង្ទីម៉ែត្រ ប្រវែងពី៣០-៥០សង្ទីម៉ែត្រ ។ រីឯផ្កាត្នោតញីមានសណ្ឋានជាពកមូលៗ ប្រវែងពី៥០-៧០សង្ទីម៉ែត្រ ដែលអាចផ្តល់ផ្លែបានចំនួនពី២០-៥០គ្រាប់ ។ ផ្លែត្នោតមានរាងមូល ពណ៌ត្នោតក្រម៉ៅនៅភាគ ខាងក្រោម និងពណ៌បៃតងនៅភាគខាងលើនៃផ្លែ ហើយប្រែពណ៌ទៅជាលឿងទុំក្រម៉ៅពេលវាចាស់-ទុំ ។ ផ្លែត្នោតមានអង្កត់ ផ្ចិតប្រមាណពី១៣-២០សង្ទីម៉ែត្រ ដែលប្រែប្រួលទៅតាមគុណភាពដី ការកៀបយកទឹក និងអាយុកាលរបស់ដើម ។ ត្នោត ជារុក្ខជាតិប្រជាប្រិយ តំណាងឱ្យសង្គមខ្មែរដែលមានវត្តមាន និងផ្តល់អត្ថប្រយោជន៍ច្រើនយ៉ាងដល់ប្រជាជាតិខ្មែរ តាំងពីសម័យ កំណកំណើតនគរខ្មែរ និងជាអត្តសញ្ញាណដែលប្រជាជនខ្មែរ សម្គាល់នូវទេសភាពទឹកដីរបស់ខ្លួន តាំងពីបុរាណកាលរហូតដល់ បច្ចុប្បន្ន ស្របនឹងពាក្យស្លោកថា "**ដើមត្នោតជាជម្រកផ្ទះខ្មែរ**" ។ កាលពីឆ្នាំ២០០៣កន្លងទៅនេះ ព្រះមហាក្សត្រនៃព្រះរាជា ណាចក្រកម្ពុជា បានស្នើឱ្យរាជរដ្ឋាភិបាលកម្ពុជាមានវិធានការទប់ ស្កាត់កុំឱ្យមានការបំផ្លាញទ្រព្យធម្មជាតិ ដូចជាព្រៃឈើ និង ដើមត្នោតជាដើម ដែលបន្ទាប់មកក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានចេញនូវសារាចរណែនាំលេខ៤៨១សរណន. កសក ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០០៣ ស្តីពីវិធានការទប់ស្កាត់ការដឹកជញ្ជូន និងធ្វើអាជីវកម្មដើមត្នោត ។ ក្នុងសង្គមខ្មែរ ដើមត្នោតមានសារៈសំខាន់ច្រើនយ៉ាងណាស់ ដូចជា : ឫសត្នោត និងផ្កាត្នោតឈ្មោលជា ឱសថបុរាណ សម្រាប់កែរោគគ្រុនចាញ់ កាមរោគ ឬរោគស្ពឹកចុងដៃ ចុងជើង ។ ដើមត្នោតអាចយកមកប្រើបាស់នៅក្នុងសំណង់លំនៅឋាន ក្រោលសត្វ ទូក ឬ សំណង់ផ្សេងទៀត ។ បច្ចុប្បន្ន ដើមត្នោតបានកែច្នៃជាផលិតផលសិប្ប កម្មដ៏មានតម្លៃក្នុងទីផ្សារ ។ ស្លឹកសម្រាប់ប្រក់ និងធ្វើ ជញ្ជាំងផ្ទះ ត្បាញកន្ទេល មួក ស្មុគ និងពេលខ្លះអាចប្រើប្រាស់ស្លឹកត្នោតសម្រាប់ចារ ឬសរសេរជំនួសស្លឹកទ្រាំងបានទៀតផង ។ ផ្លែត្នោត និងទឹកត្នោតមានឱជារសឈ្ងុយឆ្ងាញ់ពិសា ជាទីពេញនិយមនៃសង្គមខ្មែរ ។ ការផលិតស្ករត្នោតដោយរម្ងាស់ពីទឹកត្នោត គឺជាប្រពៃណីរបស់ប្រជារាស្ត្រខ្មែរតាំងពីសម័យបុរាណរហូតមកដល់បច្ចុប្បន្ន ៕

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ...០៥...បក..

# បទបញ្ជា
# ស្តីពី
# វិធានការការពារ និង អភិរក្សដើមត្នោត

ដើមត្នោត គឺជាប្រភេទរុក្ខជាតិដែលមានសារប្រយោជន៍ពិសេសច្រើនយ៉ាង និង មានចំនួនច្រើនសន្ធឹកសន្ធាប់ ព្រមទាំងបានផ្សារភ្ជាប់ជាមួយប្រវត្តិសាស្ត្រ និង វប្បធម៌ដ៏យូរលង់នៃព្រះរាជាណាចក្រកម្ពុជាយើង។ ប្រជាជនខ្មែរទាំងអស់ត្រូវមានមោទនភាព និង កិត្យានុភាពយ៉ាងក្រៃលែង ដោយសារបុព្វបុរសយើងជាច្រើនជំនាន់កន្លងមកបានខិតខំព្យាយាមដាំដុះ ថែរក្សា និង ការពារប្រភេទរុក្ខជាតិត្នោតរហូតបានបន្សល់ទុកជាកេរដំណែលនៅពាសពេញផ្ទៃប្រទេសដ៏មានតម្លៃខាងសេដ្ឋកិច្ច វប្បធម៌ ប្រវត្តិសាស្ត្រ និង បរិស្ថានឱ្យដល់ជំនាន់យើងបច្ចុប្បន្ននេះ។ អាស្រ័យហេតុនេះហើយ ទើបរាជរដ្ឋាភិបាលសម្រេចចាត់បញ្ចូលដើមត្នោតជាប្រភេទរុក្ខជាតិនិមិត្តរូបជាតិតាមរយៈព្រះរាជក្រឹត្យ លេខ.នស/រកត/០៣០៥/១៤៩ ចុះថ្ងៃទី ២១ ខែមីនា ឆ្នាំ ២០០៥ ស្តីពីការកំណត់ ប្រភេទសត្វ និង រុក្ខជាតិសម្រាប់និមិត្តរូបនៃព្រះរាជាណាចក្រកម្ពុជា ក្នុងគោលបំណងរក្សានូវកេរដំណែលនៃមរតកធម្មជាតិនេះឱ្យបានគង់វង្សជានិរន្តរ៍។

កន្លងមករាជរដ្ឋាភិបាល ដែលមានក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ជាស្ថាប័នមានសមត្ថកិច្ច បានយកចិត្តទុកដាក់ខ្ពស់ក្នុងការការពារ និង ទប់ស្កាត់ការធ្វើអាជីវកម្មដើមត្នោតដោយអនាធិបតេយ្យដោយបានដាក់ចេញនូវវិធានការនានាក៏ដូចជាសារាចរណែនាំស្តីពីវិធានការទប់ស្កាត់ការដឹកជញ្ជូន និង ការធ្វើ អាជីវកម្ម ការកែច្នៃ ដើមត្នោតក្នុងគោលបំណងការពារ ថែរក្សា និង អភិរក្សដើមត្នោត ដែលជាប្រភេទរុក្ខជាតិនិមិត្តរូបជាតិនេះ។ ទោះជាមានវិធានការអនុវត្តហើយក្តី រាជរដ្ឋាភិបាលនៅតែសង្កេតឃើញមានសកម្មភាពនៃការកាប់រំលំដើមត្នោតជាលក្ខណៈប្រមូលផ្តុំសម្រាប់ធ្វើពាណិជ្ជកម្ម ដោយសារតែមានឈ្មួញកណ្តាលជាអ្នកបំផុសឱ្យកាប់ និង ដើរប្រមូលទិញ ធ្វើអាជីវកម្មដឹកជញ្ជូន កែច្នៃ នាំចេញទៅក្រៅប្រទេស ដែលធ្វើឱ្យសកម្មភាពកាន់តែរីករាលដាល ច្រើនឡើងៗពីតំបន់មួយទៅតំបន់មួយទៀតជាបន្តបន្ទាប់ និង បង្កនូវវិនាសកម្មយ៉ាងធ្ងន់ធ្ងរដល់រុក្ខជាតិប្រភេទនេះ។ ម្យ៉ាងវិញទៀត ប្រជាកសិករខ្លះយល់ឃើញថាដើមត្នោតបានដុះក្នុងបរិវេណដីកម្មសិទ្ធិ

របស់គាត់ គាត់មានសិទ្ធិប្រើប្រាស់ និង លក់ដូរទៅតាមតម្រូវការ ដោយមិនបានពិចារណាថា ដើមត្នោតជារុក្ខជាតិដែលផ្តល់អត្ថប្រយោជន៍ច្រើនយ៉ាង យូរអង្វែង សម្រាប់ជីវភាពរស់នៅរបស់គាត់ ជារុក្ខជាតិតំណាងឱ្យនិមិត្តរូបជាតិ និង តំណាងឱ្យវប្បធម៌ខ្មែរដូចដែលមានចម្លាក់នៅលើជញ្ជាំងអង្គរវត្តជាសក្ខីភាពស្រាប់ និង មិនដែលនឹកស្មាន់ថា កេរមរតកធម្មជាតិនេះ អាចឈានទៅរកការផុតពូជពីទឹកដីយើង ក៏ដូចជាធ្វើឱ្យបាត់បង់អត្តសញ្ញាណវប្បធម៌ អរិយធម៌ និង ប្រវត្តិសាស្ត្រធម្មជាតិរបស់ជាតិឡើយ។

ស្ថិតនៅក្នុងស្ថានភាពចំពោះមុខនេះ ដើម្បីធានាបាននូវការគ្រប់គ្រង និង ការប្រើប្រាស់ដើមត្នោតប្រកបដោយនិរន្តរភាព ទោះជាក្នុងរូបភាពឯកជន គ្រួសារ សមូហភាព ឬ សាធារណៈក្តី និង ដើម្បីរក្សាបាននូវផលប្រយោជន៍សង្គម សេដ្ឋកិច្ច បរិស្ថាន និង វប្បធម៌របស់ប្រទេសជាតិ រាជរដ្ឋាភិបាលសម្រេចដាក់ចេញនូវវិធានការដូចខាងក្រោម :

១-ប្រគល់ភារកិច្ចជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ដើម្បីគ្រប់គ្រងសកម្មភាពទូទៅ ក្នុងការការពារ អភិរក្ស ដាំដុះ ប្រើប្រាស់ដើមត្នោតឱ្យមាននិរន្តរភាព។

២-ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ត្រូវបន្តផ្សព្វផ្សាយពីសារៈប្រយោជន៍របស់ដើមត្នោត និងផលវិបាកនៃការបាត់បង់ដើមត្នោតជូនប្រជាពលរដ្ឋឱ្យបានយល់ជ្រួតជ្រាប។ លើសពីនេះទៅទៀត ត្រូវបន្តណែនាំឱ្យប្រជាពលរដ្ឋបានយល់ដឹង និង ចេះប្រើប្រាស់ដើមត្នោតឱ្យអស់លទ្ធភាព និង គប្បីកាប់តែដើមត្នោតឈ្មោលដែលលែងផ្តល់ផល។

៣-ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ និង អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ត្រូវបំផុសចលនាដល់ប្រជាពលរដ្ឋឱ្យចូលរួមដាំដើមត្នោតនៅក្នុងមូលដ្ឋាន ជាពិសេសនៅរាល់ពិធីរុក្ខទិវា "៩ កក្កដា" ដើម្បីជំនួសដើមត្នោតដែលកាប់យកមកប្រើប្រាស់ផង និង ធានាបាននូវនិរន្តរភាពដើមត្នោតឱ្យនៅរាយប៉ាយពាសពេញផ្ទៃប្រទេសកម្ពុជាយើងផង។ បណ្តាខេត្តដែលគ្មានព្រៃឈើ និង តំបន់ជាប់ព្រំដែនត្រូវជំរុញចលនាដាំដើមត្នោត ដើម្បីរក្សាអនាគតមរតកធម្មជាតិនេះឱ្យបានគង់វង្ស។

៤-អាជ្ញាធរមូលដ្ឋាន ត្រូវសហការជាមួយសមត្ថកិច្ចក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ក្នុងការចុះស្រង់ស្ថិតិដើមត្នោតរបស់ប្រជាកសិករនៅគ្រប់មូលដ្ឋាន។

៥-អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ និង អាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ ត្រូវសហការជាមួយសមត្ថកិច្ចក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ចាត់វិធានការទប់ស្កាត់ជាបន្ទាន់ រាល់សកម្មភាពកាប់រំលំជាលក្ខណៈប្រមូលផ្តុំ ដែលនាំមកនូវវិនាសកម្មដល់ដើមត្នោត។

៦-ប្រជាពលរដ្ឋគ្រប់រូបត្រូវចូលរួមថែរក្សាការពារ អភិរក្ស និង ត្រូវចូលរួមដាំដើមត្នោតនៅលើដីកម្មសិទ្ធិរបស់ខ្លួន។

៧-កម្មសិទ្ធិករដើមត្នោត ត្រូវបានរក្សាសិទ្ធិក្នុងការប្រើប្រាស់ដើមត្នោត និង ផលិតផលពីដើមត្នោតរបស់ខ្លួនប្រកបដោយនិរន្តរភាព។

៨-ត្រូវបានអនុញ្ញាតឱ្យមានការកែច្នៃជាលក្ខណៈប្រពៃណីនូវគ្រឿងចម្លាក់ សម្ភារៈប្រើប្រាស់វត្ថុអនុស្សាវរីយ៍ ដែលធ្វើពីឈើត្នោតប្រកបដោយការសន្សំសំចៃខ្ពស់ និងផលិតផលត្នោតកែច្នៃផ្សេងទៀត សម្រាប់បម្រើទីផ្សារក្នុងស្រុក ឬក្រៅស្រុក ដើម្បីបង្កើនមុខរបរជូនប្រជាពលរដ្ឋដោយមានការអនុញ្ញាត ពីសមត្ថកិច្ចក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ។

៩-ហាមឃាត់ដាច់ខាតចំពោះអាជីវករទាំងឡាយណាដែលបំផុស និង ជំរុញចលនាកាប់ដើមត្នោត ជាលក្ខណៈប្រមូលផ្តុំ ដើម្បីធ្វើការប្រមូលទិញ ការដឹកជញ្ជូន ការធ្វើសន្និធិក្នុងគោលបំណងពាណិជ្ជកម្ម ឬ ការបង្កើតរោងចក្រ រោងសិប្បកម្មកែច្នៃដើមត្នោត ឈើត្នោតជាលក្ខណៈឧស្សាហកម្ម ឬ ក្នុងគោលបំណងនាំចេញដើមត្នោត ឬ ឈើត្នោត។

១០-អាជ្ញាធរមានសមត្ថកិច្ចនៅតាមច្រកទ្វារព្រំដែន ត្រូវហាមឃាត់ដាច់ខាតការនាំចេញដើមត្នោតឈើត្នោតទៅក្រៅប្រទេស ។

១១-ការនាំចេញសំណាកដើមត្នោត ឈើត្នោតកែច្នៃ ផលិតផលត្នោតក្នុងគោលបំណងសិក្សាស្រាវជ្រាវ តាំងពិព័រណ៍ ឬ ដើម្បីប្រយោជន៍សាធារណៈផ្សេងទៀត ត្រូវសម្រេចដោយរាជរដ្ឋាភិបាល។

១២-អាជីវករទាំងឡាយណាដែលប្រព្រឹត្តល្មើសចំពោះការហាមឃាត់ក្នុងបទបញ្ជានេះ នឹងត្រូវទទួលការផ្តន្ទាទោសតាមច្បាប់ជាធរមាន។

ទទួលបានបទបញ្ជានេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ក្រសួងមហាផ្ទៃ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ត្រូវជំរុញការផ្សព្វផ្សាយឱ្យបានទូលំទូលាយ និង ចាត់ចែងអនុវត្តប្រកបដោយប្រសិទ្ធភាពខ្ពស់ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ[illegible] ឆ្នាំ ២០០៦

ហ៊ុន សែន

កន្លែងទទួល:
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
-ក្រសួង ស្ថាប័នពាក់ព័ន្ធ
-សាលាខេត្ត ក្រុង
-ឯកសារ-កាលប្បវត្តិ